# សម ល្មម

*ទ្រីណាមិនចូលចិត្តការខុសប្លែកពីក្មេងដទៃទេ ។*

ដោយ រីអាត អិម រ៉មនី
ទស្សនាវដ្ដីសាសនាចក្រ
( ផ្អែកទៅលើដំណើររឿងពិត )

« ឯងល្អិតម្ល៉េះ ! » សាស្សាបាននិយាយ ។ « យើងគួរហៅឯងថា ទ្រីណាល្អិត » ។

ទ្រីណាព្យាយាមញញឹម ។ ក្មេងផ្សេងទៀតនៅសាលារៀនបានចំអន់នាងច្រើនណាស់ដោយសារតែនាងមានមាឌល្អិត ។ នាងកើតមកមានមាឌល្អិត ហើយនាងមិនធំធាត់លឿនដូចជាក្មេងផ្សេងទៀតទេ ។ ប៉ុន្តែនាងមិនចូលចិត្តឈ្មោះទ្រីណាល្អិតឡើយ ។ នាងមិនចូលចិត្តការខុសប្លែកពីក្មេងដទៃទេ ។

នៅពេលពួកគេចេញលេងនៅខាងក្រៅ ម៉ាកស្ស បាននិយាយថា « ឯងល្អិតណាស់ ឯងប្រហែលជានៅតែប៉ុណ្ណឹង » ។

ទ្រីណាបាននិយាយថា « ខ្ញុំដឹងថា ខ្ញុំល្អិត » ។ « ប៉ុន្តែខ្ញុំមិនអាចផ្លាស់ប្ដូរវាបានទេ ។ តោះយើងទៅលេងវិញ » ។

ទ្រីណាបានរត់ទៅលេងបាល់ជាមួយនឹងក្មេងផ្សេងទៀត ។ ពួកគេបានទាត់បាល់ទៅវិញទៅមក ។ ពួកគេសប្បាយរីករាយជាមួយគ្នា ។

ប៉ុន្តែ មិនយូរប៉ុន្មាន ទ្រីណានឿយហត់ណាស់ ។ នាងបានដើរយឺតៗចេញពីការលេងបាល់នោះ ហើយអង្គុយនៅលើស្មៅ ។

រំពេចនោះមិត្តរបស់នាងឈ្មោះចូស៊ីបានដើរមក ។ ចូស៊ីនៅក្នុងថ្នាក់កុមារជាមួយនឹងនាងនៅឯព្រះវិហារដែរ ។

« ឯងមិនអី ទេហ្អី ? » ចូស៊ីបានសួរ ។

ទ្រីណាបានពោលថា « មែនហើយ » ។ « ខ្ញុំចង់សម្រាកបន្តិច ។ ខ្ញុំនឿយហត់ណាស់ ពេលខ្ញុំរត់ច្រើនពេក ។ សួតខ្ញុំមិនសូវល្អទេ » ។

ចូស៊ីបានអង្គុយចុះជិតទ្រីណា ។ ពួកគេបានដកស្មៅធ្វើចិញ្ចៀន និងកងដៃតូចៗ ។ ពួកគេបាននិយាយគ្នាអំពីសាលារៀន ព្រមទាំងមិត្តភក្តិ និងកិច្ចការសាលា ។

ចូស៊ីបាននិយាយថា « ខ្ញុំបានស្ដាប់ឮអ្វីដែលសាស្សាបាននិយាយ » ។ « ខ្ញុំសោកស្ដាយដែលនាងហៅឯងថា ទ្រីណាល្អិត » ។

ទ្រីណាបានងក់ក្បាល ។

« ប៉ុន្តែខ្ញុំគិតថាមាឌឯងសមល្មមហើយ ! » ចូស៊ីបាននិយាយ ។

ទ្រីណាបានញញឹម ។ នាងបានហុចកងដៃស្មៅដែលនាងបានធ្វើទៅឲ្យចូស៊ី ។

លុះថ្ងៃអាទិត្យក្រោយទ្រីណាបានត្រៀមខ្លួនជាស្រេចទៅព្រះវិហារ ។ នាងបានស្លៀករ៉ូប ហើយសិតសក់របស់នាង ។ បន្ទាប់មក នាងបានសម្លឹងមើលស្បែកជើងតូចរបស់នាងនៅក្នុងទូរ ។ នាងប្រាកដក្នុងចិត្តថា គ្មានក្មេងណាផ្សេងទៀតនៅក្នុងថ្នាក់កុមារពាក់ស្បែកជើងតូចបែបនេះឡើយ ។

ទ្រីណាបានដើរអូសជើង ពេលនាងដើរនៅច្រកដើរក្នុងព្រះវិហារ ។ ពេលនាងដើរទៅថ្នាក់កុមារ ចូស៊ីកំពុងរង់ចាំនៅខាងក្រៅ ។

« យើងមានរឿងដ៏ភ្ញាក់ផ្អើលមួយសម្រាប់ឯង ! » ចូស៊ីបាននិយាយ ។ « មកទៅមើល ! »

ពេលទ្រីណាបានដើរចូលទៅក្នុងបន្ទប់ ក្មេងផ្សេងទៀត និងគ្រូរបស់ពួកគេ បងស្រីបុតកំពុងចង្អុលទៅក្ដារខៀនដែលបានតុបតែងដោយពណ៌ស្រស់ស្អាត ។ វាមានរូបបេះដូងបិតនៅលើនោះ ។ បេះដូងនីមួយៗមានសរសេរអក្សរថា « ទ្រីណាមានស្នាមញញឹមដ៏ស្រស់ស្អាត ! ទ្រីណាមានចិត្តល្អ ! »

ចូស៊ីបានសួរថា « តើឯងចូលចិត្តទេ ? » « បងស្រីបុត ជួយយើងធ្វើវា » ។

ទ្រីណាបាននិយាយថា « ខ្ញុំ ពេញចិត្តណាស់ ! » ។ « អរគុណ » ។

បងស្រីបុតបាននិយាយថា « យើងចង់រំឭកប្អូនអំពីសេចក្ដីពិតដ៏ធំមួយ » ។ « ព្រះវរបិតាសួគ៌ស្រឡាញ់យើងម្នាក់ៗ ។ ទាប ។ ខ្ពស់ ។ ធំ ។ តូច ។ មិនសំខាន់ចំពោះទ្រង់ទេ ។ យើងគ្រប់គ្នាគឺជាបុត្រាបុត្រីរបស់ទ្រង់ ហើយទ្រង់ស្រឡាញ់យើងទាំងអស់គ្នា » ។

ទ្រីណាបានមើលទៅរូបបេះដូងទាំងនោះនៅក្ដារខៀន ហើយញញឹម–ពព្រាយ ។ ●

*ដំណើររឿងនេះបានកើតឡើងនៅ ស.រ.អា. ។*

